## និយាយពីអ្វី?

តាមការស្រាវជ្រាវបានបង្ហាញឱ្យឃើញថា ឪពុកម្តាយ ជនជាតិអាស៊ីយើង ចង់និយាយប្រាប់កូនពីរឿងសេព្វកាមដែរ តែមិនដឹងថាចាប់ផ្តើមដំណើរ

នឹងប្រព្រឹត្តរបៀបណា?

- នៅក្នុងការសិក្សានឹងស្រាវជ្រាវបានឃើញថា ចំនួនពាក់កណ្តាលយុវនារីជនជាតិអាស៊ីយើងមានការពិបាក
- ពិគ្រោះគ្នាជាមួយម្តាយក្នុងរឿងការបន្តពូជ ហើយមួយភាគបីទៀត នៅក្នុងគ្រួសារ មិនដែលនិយាយ
- ពីដំណើរនៃការមានគត៌ ឬ រោគឆ្លងនៃការសេព្វកាម ឬ ការពារមិនឱ្យមានកូន ។
- គ្រូពេទ្យបាននិយាយថា បើសិនជាឪពុកម្តាយជនជាតិអាស៊ីយើង បាននិយាយទុកជាមុន ហើយប្រាប់ពន្យល់កូន ពីហេតុផលរឿងសេព្វកាម គឺជារឿងស្រួលបន្តការពន្យល់រហូតដល់ពួកគេធំពេញវ័យ ចេះគិតខ្លួនឯង ។
- ថ្វីត្បិតតែយុវវ័យរបស់ជនជាតិអាស៊ីយើងមានការរួមកាមភេទយឺតយូរជាងជនជាតិដទៃទៀតមែនក៏ដោយក្តី ក៏លទ្ធផលអាក្រក់អាចមានដូចៗគ្នា ។

គ្រូបង្រៀនបាននិយាយថា កូនសិស្ស ឃើញ ឬ ឮរឿង ការសេព្វកាម នេះតាមរយៈមិត្តភក្តិ ទូរទស្ស ខ្សែភាពយន្ត និង រួមជាមួយទស្សនាវដ្តីផង ។

ហេតុនេះហើយគឺជាការសំខាន់ណាស់ដែលឪពុកម្តាយ ត្រូវតែជួយណែនាំក្នុងរឿងនេះដល់កូនចៅដោយត្រឹមត្រូវ ហើយ ឱ្យគេចេះសំរេចចិត្តបានល្អក្នុងរឿងនេះ ។

ACRJ:
ជួយគាំទ្រក្រុមគ្រួសារជនជាតិអាស៊ីតាំងពីឆ្នាំ១៩៨៩ យើងបានជួយធ្វើការ និង ខំបង្កើនអំណាចដល់ឪពុកម្តាយ របស់ក្រុមគ្រួសារយុវវ័យឱ្យ ចេះកែឆ្នៃពន្យល់ ក្នុងរឿងកាមសាស្សនេះដោយឱ្យគេចេះ សំរេចចិត្តយ៉ាងត្រឹមត្រូវ នឹងចេះការពារកុំឱ្យមានកាមរោគ ។

ACRJ:
កំពុងតែធ្វើការជួយគ្រប់ប្រទេសដើម្បីផ្លាស់ប្តូរនូវច្បាប់ដោយជួយ គាំទ្រក្រុមគ្រួសាររបស់អ្នក នឹងចូលរួមក្នុងការស្ថាបនាក្រុមគ្រួសារអ្នក ឱ្យមានកំលាំងខ្លាំងឡើង ។

ដោយពិនិត្យតាមរយៈគេហដ្ឋទំព័រ
www.reproductivejustice.org/strong-families

©2010 Asian Communities for Reproductive Justice
1440 Broadway, Suite 301, Oakland, CA 94612
Phone: 510-663-8300
www.reproductivejustice.org



# ស្ថាបនាឱ្យគ្រួសារមាំមួន

## គឺនិយាយអំពីការសេព្វកាម នឹងរូបរាងកាយរបស់យើង



# តើអ្វីទៅដែលឪពុក ម្ដាយចង់បាន

ខ្ញុំចង់រក្សានូវទំនៀមទំលាប់នឹងតម្លៃរបស់សង្គមជាតិយើង
ហើយជាការសំខាន់ទៀតយើងត្រូវតែនិយាយពន្យល់ប្រាប់ពួកគេ ។

ខ្ញុំមានអារម្មណ៏ដឹកក់ក្ដៅនូវពេលដែលបាននិយាយពីរឿងសេព្វកាមនេះ
ជាមួយកូនៗ ទោះបីជាខ្ញុំមិនមានចម្លើយ គ្រប់បែបយ៉ាងក៏ដោយ
ក៏ប៉ុន្តែខ្ញុំនៅតែមានភាពកក់ក្ដៅនៅពេលដែលបានពិគ្រោះពីរឿងនេះ ។
ខ្ញុំចង់ឱ្យពួកគេបានទទួលការចេះដឹងយ៉ាងត្រឹមត្រូវ
ដែលអាចជួយពួកគេឱ្យចេះសំរេចចិត្តដ៏ល្អនឹងត្រឹមត្រូវដោយខ្លួនឯង
ក្នុងរឿងនេះ ។

ខ្ញុំចង់បានអ្វីៗសំរាប់កូនចៅរបស់យើងឱ្យបានផលល្អឡើងជាពិសេសនូវ
ពេលដែលគេធំពេញវ័យ ។
ខ្ញុំមិនមែនជាអ្នកបង្រៀនពីរឿងសេព្វកាមជាមួយគ្នានៅក្នុងសាលារៀនទេ
តែខ្ញុំចង់ឱ្យកូនក្មេងបានចេះដឹង
ក្នុងរឿងនេះដោយត្រឹមត្រូវ ។

ខ្ញុំចង់ឱ្យកូនខ្ញុំមានការចេះដឹង
ហើយគេអាចចេះសំរេចចិត្ត
ដោយជោគជយ័ នឹងសុខភាពល្អ ។





# ចាប់ផ្ដើមប្រមូលការពិភាគសារ

រៀងរាល់ថ្ងៃគ្រប់ពេលវេលាឮពាក្យថាសេព្វកាមនេះជាញឹកញាប់
កន្លែងនេះហើយដែលជាឧទាហរអាចអនុញ្ញាតិឱ្យអ្នកចាប់ផ្ដើមពិភាគសារ ។

TV: ទូរទស្ស ពេលដែល គេគិតថារួមកាមជាមួយគ្នា
ពាក្យមានផ្ទៃពោះក៏ចាប់ផ្ដើមបញ្ចុំងឡើងហើយមានសំនួរ សួរដូចពាក្យនេះថា:

- តើពេលណាទៅទើបអ្នកអាចសេព្វកាមបាន?
- តើពេលណាទៅទើបអ្នកអាចសេព្វកាមជាមួយគ្នាបាន?

School: សាលារៀន ពេលណាក្មេងៗនិយាយពីរឿងនេះ ក្នុងសាលារៀន
ហើយមានរឿងនេះកើតឡើង តើអ្នកអាចសួរសំនួរនេះដូចម្ដេចទៅ?

- តើនៅថ្នាក់រៀនរបស់អ្នកបានបង្រៀនពីរឿងការសេព្វកាមជាមួយគ្នាទេ?
- នៅពេលដែលមានការណាត់ចេញដើរលេងជាមួយគ្នា
  តើអ្នកមានអារម្មណ៏ថា មានត្រូវការបង្ខំពីដៃគូរអ្នក?
- នៅក្នុងសាលារៀនអ្នក តើមានក្មេងស្រីៗមាន មានគត៏ ឬទារកដែរឬទេ?

Puberty: ពេលពេញវ័យកម្លោះ ក្រមុំ ពេលដែលកូនយើង
មានរូបរាងឬបែកសំឡេង នោះជាពេលដែលគេពេញវ័យ កម្លោះឬក្រមុំ
អ្នកអាចសួរសំនួរដូចនេះ

- តើកូនឯងមានអារម្មណ៏ពីរូបរាងដែលកំពុងផ្លាស់ផ្ទូរយ៉ាងណាដែរ?
- តើអ្នកមានដឹងថា មានចលនាស្រើបស្រាលក្នុងចំណែកខ្លួនអ្នក ហេតុអ្វីដែរ?
- តើអ្នកដឹងទេថាអ្នកអាចមានផ្ទៃពោះ

Dating: ពេលណាត់ជួបគ្នាជាមួយសង្សារ
ពេលដែលអ្នកបានឃើញហើយដឹងថាគេទាំងពីរនាក់នៅមួយគ្នា
អ្នកអាចសួរសំនួរដូចតទៅនេះ

- បើមនុស្សពីរនាក់ជាសង្សារនឹងគ្នា
  តើអ្នកគិតថាគេទាំពីរនាក់នឹងសេព្វកាមជាមួយគ្នាឬ?
- បើមានអ្នកណាម្នាក់បង្ខំឱ្យអ្នករួមសេព្វកាមជាមួយ
  តើអ្នកអាចរកផ្លូវណាពោលថាមិនយល់ព្រម ឬអាចនិយាយថាទេ!
- ហេតុអ្វីបានជាមនុស្សទូទៅគិតថាក្មេងស្រីៗ
  នៅក្នុងសាលារៀនសុទ្ធតែមានការសេព្វកាមជាមួយគ្នា?
- តើអ្វីទៅបានជាមនុស្សទូទៅគិតថាក្មេងប្រុសៗនៅសាលារៀនសុទ្ធតែមានកា
  រសេព្វកាម?

# តើអ្វីទៅ យុវ័វយ័ ដែលចង់បាន



ខ្ញុំគិតថាបើខ្ញុំស្រឡាញ់មនុស្ស ទាំងពីរ ភេទ
យុវ័ជន ឬយុវ័នារី ។
ហើយខ្ញុំចង់និយាយប្រាប់ពួកគាត់
ឱ្យដឹង ក៏ប៉ុន្តែខ្ញុំខ្លាចពួកគាត់ប្រកាន់ខ្មាស់គេ
មិនព្រមទទួលស្គាល់ ។ ហើយ
បើសិនជាពួកគាត់ដឹងថាខ្ញុំជាមនុស្សដែល
ស្រឡាញ់មនុស្សមានភេទដូចគ្នា
ពួកគាត់ថែមទាំងបណ្ដេញខ្ញុំចេញពីផ្ទះទៀត ។

ខ្ញុំគិតថាបើសិនជាខ្ញុំមានសំនួរពីការសេព្វកាមនេះ
ខ្ញុំមានអារម្មណ៏ថាដូចខ្ញុំបានយករឿងអាសអាភាស
ឱ្យដល់ក្រុមគ្រួសារ ពី ព្រោះ ពួកគាត់គិតថាខ្ញុំជាកូនប្រុសមិនល្អ ។

ពួកគាត់គិតថាខ្ញុំជាក្មេងដែលមិនដឹងអ្វីសោះ
ក៏ប៉ុន្តែខ្ញុំអាចដឹងហើយចេះសំរេចចិត្តខ្លួនឯងបានល្អនៅពេលដែលខ្ញុំ
បានយល់ដឹងពីរឿងនេះត្រឹមត្រូវ
ព្រមទាំងមានការគាំទ្រពីចាស់ទុំដែលខ្ញុំមានសេចក្ដីទុកចិត្តជាទីបំផុត ។

ខ្ញុំបានឮពួកគាត់និយាយជារឿយៗថាកុំឱ្យសេព្វកាម
ក៏ប៉ុន្តែពួកគាត់មិនដែលពន្យល់រឿងនេះប្រាប់ខ្ញុំឡើយ ។
ការពិតខ្ញុំចង់រៀនពីការសេព្វកាមនេះ មិនមែនថាខ្ញុំ
មានការសេព្វកាមទេ ហើយនេះក៏មិនមែនមានន័យថា
ខ្ញុំចង់សេព្វកាមដែរ ។

